00601853 F6

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification):
13-Sep-2010, 09:05
Sann Rada

**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ៖** ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

**ដាក់ទៅ៖** អង្គជំនុំជម្រះតុលាការកំពូល

**ថ្ងៃដាក់៖** ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០

**ភាគីអ្នកដាក់៖** សហមេធាវីជាតិការពារក្តីលោក **កាំង ហ្គេកអ៊ាវ** ហៅ "**ឌុច**"

**ភាសាដើម៖** **ភាសាខ្មែរ**

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ស្នើដោយភាគីអ្នកដាក់តម្កល់៖ **សាធារណៈ:**

ចំណាត់ថ្នាក់សម្រេចដោយសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ៖

លក្ខន្តិកៈនៃចំណាត់ថ្នាក់៖

ការពិនិត្យចំណាត់ថ្នាក់បណ្តោះអាសន្នឡើងវិញ៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿងនិងឯកសារ៖

ហត្ថលេខា៖

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 10 / 09 / 2010
ម៉ោង (Time/Heure): 15:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

---

**សំណើររបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" សុំពន្យាពេលកំណត់សម្រាប់ដាក់សារណាបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រម ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ របស់អង្គជំនុំជម្រះ សាលាដំបូង**

---

**អ្នកដាក់ឯកសារ៖**

**សហមេធាវីការពារក្តីជនជាប់ចោទ:**

**កាំង ហ្គេកអ៊ាវ** ហៅ "**ឌុច**"

មេធាវី **ការ សាវុត្ថ**

មេធាវី **កង ឫទ្ធារី**

**អ្នកទទួលឯកសារ៖**

**អង្គជំនុំជម្រះតុលាការកំពូល:**

ចៅក្រម **គង់ ស្រីម** ប្រធាន

ចៅក្រម **Motoo NOGUCHI**

ចៅក្រម **សោម សិរីវឌ្ឍ**

ចៅក្រម **A. KLONOWIECKA-MILART**

ចៅក្រម **ស៊ិន វិន**

ចៅក្រម **C.N.JAYASINGHE**

ចៅក្រម **យ៉ា ណារិន**

00601854

F6

០០១/១៨-០៧-២០០៧-អ.វ.ត.ក /អ.ជ.ត.ក

**<u>សហព្រះរាជអាជ្ញា</u>**

លោកស្រី **ជា លាង**

លោក **Andrew CAYLEY**

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី</u>**

| | | |
|---|---|---|
| មេធាវី គង់ ពិសី | មេធាវី Silke STUDZINSKY | មេធាវី Annie DELAHAIE |
| មេធាវី ហុង គីមសួន | មេធាវី Martine JACQUIN | មេធាវី Elizabeth RABESANDRATANA |
| មេធាវី យុង ផានិត | មេធាវី Philippe CANNONE | មេធាវី Karim KHAN |
| មេធាវី គីម ម៉េងឃី | មេធាវី Pierre Olivier SUR | មេធាវី Fabienne TRUSSES-NAPROUS |
| មេធាវី ម៉ុច សុវណ្ណារី | មេធាវី Alain WERNER | មេធាវី Christine MARTINEAU |
| មេធាវី ទី ស្រ៊ីនណា | មេធាវី Brianne McGONIGLE | |

## I. សេចក្តីផ្តើម

១. កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ សហមេធាវីការពារក្តី **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ("ជនជាប់ចោទ") បានដាក់ការជូនដំណឹងអំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់សាលាដំបូងចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ដែលបានផ្តន្ទាទោសជនជាប់ចោទឲ្យជាប់ពន្ធនាគារសរុបចំនួន៣៥ឆ្នាំ[១] ។

២. អនុលោមតាមវិធាន ១០៧(៤) នៃវិធានផ្ទៃក្នុង សារណាបណ្តឹងសាទុក្ខត្រូវដាក់ក្នុងរយៈពេល៦០ថ្ងៃ បន្ទាប់ពីការដាក់សេចក្តីជូនដំណឹងពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង។ វិធាន៣៩(៤) នៃវិធានផ្ទៃក្នុង តាមការផ្តួចផ្តើមរបស់ខ្លួន ឬតាមរយៈពាក្យសុំរបស់ភាគីដែលពាក់ព័ន្ធ បានផ្តល់អំណាចឲ្យអង្គជំនុំជម្រះ ពន្យាពេលកំណត់នៃការដាក់សារណា។ ដោយពិចារណាពីទំហំ និងភាពស្មុគស្មាញរបស់រឿងក្តី បញ្ហាថ្មីៗដែលត្រូវបានលើកឡើង និងរចនាសម្ព័ន្ធរបស់ក្រុមការពារក្តីរបស់ជនជាប់ចោទ សហមេធាវីការពារក្តីស្នើសុំឲ្យអង្គជំនុំជម្រះតុលាការកំពូលពន្យាពេល **៣០ថ្ងៃ** សម្រាប់ដាក់សារណានៅក្នុងរឿងក្តីនេះ ។

## II. មូលហេតុនៃសំណើ

៣. យោងតាមមាត្រា៣៥(ខ)(ថ្មី) នៃច្បាប់បង្កើត **អ.វ.ត.ក** ជនជាប់ចោទមានសិទ្ធិទទួលបាន "ពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីរៀបចំការការពារខ្លួន" ។ សិទ្ធិនេះគឺយកចេញដោយផ្ទាល់ពីមាត្រា ១៤.៣(ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនេះត្រូវបានគេយកទៅអនុវត្តយ៉ាងទូលំទូលាយចំពោះនីតិវិធីព្រហ្មទណ្ឌទាំងមូល[២]។ ដូចដែលតុលាការអឺរ៉ុបសិទ្ធិមនុស្សបានលើកឡើងថាការការពារការជម្រះក្តីដោយ

---

[១] សំណុំរឿងលេខៈ០០១/១៨-០៧-២០០៧/អជសដ, សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ប្រឆាំងទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ខែកក្កដា ឆ្នាំ២០១០, ឯកសារលេខៈE188/8។

[២] រឿងក្តី Delcourt តទល់នឹង ប្រទេសបែលហ្ស៊ិក, ECHR, ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧០។

យុត្តិធម៌បែបនេះ "មិនបានបញ្ឈប់ការសម្រេចដោយសាលាដំបូងឡើយ" ប៉ុន្តែ ការការពារការជម្រះក្តីដោយយុត្តិធម៌នេះបានពន្លាតដល់ដំណើរការនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ ហើយការការពារការជំនុំជម្រះក្តីដោយយុត្តិធម៌នេះត្រូវតែបានប្រកាន់ខ្ជាប់រហូតដល់មានសាលក្រមស្ថាពរ[៣]។ ដើម្បីការពារសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវពេលវេលា និងលក្ខណៈគ្រប់គ្រាន់ក្នុងការរៀបចំការពារខ្លួន មេធាវីការពារក្តីដាក់សំណើសុំពន្យាពេលវេលាកំណត់សម្រាប់ដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន ដោយសំអាងលើហេតុផលដូចខាងក្រោម៖

i. ទំហំ និងភាពស្មុគស្មាញនៃរឿងក្តីនេះ តម្រូវឲ្យមានការពន្យាពេលក្នុងការរៀបចំសារណា ។ ការជំនុំជម្រះក្តីរបស់ជនជាប់ចោទចំណាយពេលស្ទើរតែមួយឆ្នាំ ដោយមានឯកសារសំណុំរឿងជាច្រើនទំព័រ។ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងមានកម្រាស់ជាង៤០០ទំព័រជាភាសាខ្មែរ ។ ការស្រាវជ្រាវបន្ថែម និងការពិចារណា គឺជាកត្តាចាំបាច់សម្រាប់មេធាវីការពារក្តីក្នុងការឆ្លើយតបឲ្យបានពេញលេញ និងឲ្យសាកសមទៅនឹងទំហំនៃសាលក្រមនេះ ។

ii. ដើម្បីធ្វើការសម្រេចអំពីអ្វីទៅដែលបង្កើតបាន "ពេលវេលាគ្រប់គ្រាន់"សម្រាប់ដាក់សារណា អង្គជំនុំជម្រះគួរតែពិចារណាពីកាលៈទេសៈជាក់លាក់នៃរឿងក្តីនេះ ។ នៅក្នុងសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានធ្វើសេចក្តីប្រកាសសំខាន់ៗជាច្រើនទៅលើអង្គហេតុ និងអង្គច្បាប់ ។ សារៈសំខាន់នៃសំណុំរឿង០០១ ដែលជារឿងក្តីដំបូងរបស់ **អ.វ.ត.ក** បានបង្កឲ្យមានបញ្ហាប្រឈមដល់មេធាវីការពារក្តី ដូច្នេះវាតម្រូវឲ្យមានការពន្យាពេលវេលាកំណត់ក្នុងការដាក់សារណារបស់មេធាវីការពារក្តី ។

iii. ការពន្យាពេលកំណត់ដើម្បីដាក់សារណារបស់មេធាវីការពារក្តី នឹងផ្តល់វិធានការជាដំណោះស្រាយមួយចំនួនចំពោះវិសមភាពនៃមធ្យោបាយដែលមានចំពោះភាគីទាំងអស់ នៅក្នុងរឿងក្តីនេះ ។ ក្រុមអ្នកច្បាប់របស់ជនជាប់ចោទមានគ្នាតែបួននាក់ប៉ុណ្ណោះ ពោលគឺសហមេធាវីពីរ

---

[៣] រឿងក្តី Monnell និង Morris តទល់នឹង ចក្រភពអង់គ្លេស,ECHR, ចុះថ្ងៃទី២ ខែមិនា ឆ្នាំ១៩៨៧, កថាខណ្ឌទី៥៤។

នាក់ អ្នកគ្រប់គ្រងសំណុំរឿងម្នាក់ និងទីប្រឹក្សាផ្នែកច្បាប់ម្នាក់ ។ នៅអំឡុងពេលសវនាការនាពេលកន្លងទៅ ការិយាល័យសហព្រះរាជអាជ្ញាមានក្រុមអ្នកច្បាប់ច្រើនជាងក្រុមមេធាវីការពារក្តីរហូតដល់ទៅបីបួនដងឯណោះ ។ ដូចគ្នានេះដែរចំនួនមេធាវីការពារក្តីសម្រាប់ជនជាប់ចោទក៏ត្រូវមានចំនួនច្រើនផងដែរ នៅពេលត្រៀមរៀបចំការការការពារក្តីឱ្យជនជាប់ចោទ ។ មេធាវីការពារក្តីក៏ត្រូវការពេលវេលាគ្រប់គ្រាន់ក្នុងការពិចារណាពីការចូលអន្តរាគមន៍ដោយមេធាវីនៃដើមបណ្តឹងរដ្ឋប្បវេណីដែលមានគ្នារហូតទៅដល់១៧នាក់ ។ បើពិនិត្យពីវិសមភាពនៃធនធានផ្នែកច្បាប់នៅពេលបច្ចុប្បន្ននេះ ការពន្យារយៈពេលកំណត់សម្រាប់ដាក់សារណារបស់មេធាវីការពារក្តី គឺពិតជាសមហេតុផល ។

iv. បន្ទាប់ពីការចេញសាលក្រមកាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ភ្លាម ជនជាប់ចោទបានជ្រើសរើសបណ្ឌិត **កង ឫទ្ធារី** ឱ្យធ្វើជាសហមេធាវីការពារក្តីនៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន ។ ក្នុងនាមជាមេធាវីដែលទើបតែងតាំងថ្មីម្នាក់ លោកបណ្ឌិត **កង ឫទ្ធារី** ត្រូវការពេលវេលាបន្ថែមទៀតដើម្បីពិនិត្យនីតិវិធីនៃការជំនុំជម្រះក្តី និងសិក្សាពីសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ។

**សូមកត់សំគាល់ថា** តាមការពិនិត្យតុលាការដទៃទៀតលើបណ្តឹងសាទុក្ខដែលមានទំហំ និងភាពស្មុគស្មាញប្រហាក់ប្រហែលគ្នានេះ បានផ្តល់នូវពេលកំណត់សម្រាប់ដាក់សារណាវែងជាងនៅ **អ.វ.ត.ក** ។ នៅតុលាការ ICTY, ICTR និងតុលាការពិសេសសម្រាប់ប្រទេសលីបង់ (Special Tribunal for Lebanon) អ្នកប្តឹងសាទុក្ខ ត្រូវបានគេផ្តល់រយៈពេល**៧៥ថ្ងៃ**ដើម្បីបំពេញកិច្ចការដូចគ្នានេះ[៤]។ តុលាការ ICTR បានផ្តល់អំណាចឱ្យអង្គជំនុំជម្រះរបស់ខ្លួន ដើម្បីពន្យាពេលកំណត់ដាក់បន្ថែមនៅក្នុងកាលៈទេសៈពិសេស ។ នៅក្នុងការទទួលស្គាល់ពីបញ្ហាច្បាប់ថ្មី ឬ ភាពស្មុគស្មាញនៃបញ្ហាច្បាប់ក្នុងបណ្តឹងសាទុក្ខ ដែលករណីទាំងពីរនេះក៏កើតឡើងនៅក្នុងរឿងក្តីនេះ ដូច្នេះការពន្យារយៈពេលកំណត់

---

[៤] វិធាន១១១(ក) ICTY RPE, វិធាន១១១(ក) ICTR RPE,វិធាន១៨២(ក) STL RPE។

តែងត្រូវបានអនុញ្ញាត[៥] ។ នៅតុលាការទាំងបីខាងលើ ភាគីអាចដាក់សារណានៃបណ្តឹងសាទុក្ខក្នុងរយៈពេល **១៥ថ្ងៃ** នៅក្នុងការឆ្លើយតបទៅនឹងគូបដិបក្ខនៃបណ្តឹងសាទុក្ខ ដែលប្រឆាំងនឹងមេធាវីដែលបានដាក់សារណាលើកដំបូង[៦]។ ប៉ុន្តែវិធានផ្ទៃក្នុងរបស់ **អ.វ.ត.ក** មិនបានចែងពីសិទ្ធិបែបនេះទេ ដូច្នេះហើយ **អ.វ.ត.ក** គួរតែងាកទៅរកការអនុវត្តធន្ទានុសិទ្ធិជាជម្រើសមួយដែលអនុគ្រោះជាងនេះដល់ការពន្យាពេលកំណត់ក្នុងការដាក់សារណា ដោយទទួលស្គាល់នូវកាលៈទេសៈពិសេសដែលបានលើកឡើងរបស់មេធាវីការពារក្តីស្របតាមវិធាន៣៩(៤) ។

## III. **សេចក្តីសន្និដ្ឋាន**

៤. អាស្រ័យលើហេតុផលដូចដែលបានបញ្ជាក់ពីខាងលើ មេធាវីការពារក្តីស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលពន្យាពេលកំណត់សម្រាប់ដាក់សារណា **៣០ថ្ងៃ** បន្ថែមទៀត ។/

| | | | |
|---|---|---|---|
| ១០ កញ្ញា ២០១០ | សហមេធាវីជាតិ<br>មេធាវី **ការ សាវុត្ថ**<br>មេធាវី **កង ឫទ្ធារី** | ភ្នំពេញ | [signature]<br>[signature] |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |

---

[៥] វិធាន១១៦ ICTY RPE

[៦] វិធាន១១៣ ICTY, វិធាន១១៣ ICTR RPE, វិធាន១៨៥(ក) STL RPE។